ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

## ជូនចំពោះ
## ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ មន្ត្រីរាជការ
## និងបុគ្គលិក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ខ្ញុំសូមប្រសិទ្ធពរដ៏កក់ក្ដៅជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ព្រមទាំងក្រុមគ្រួសារ សូមមានសុខភាពល្អបរិបូរណ៍ សុភមង្គល វិបុលសុខ កំលាំងខ្លាំងក្លា ប្រាជ្ញាវាងវៃ និងអាយុយឺនយូរ ដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយការបរទេស ស្របតាមកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា នាំមកនូវវឌ្ឍនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ឱ្យកាន់តែរីកចំរើនលើឆាកអន្តរជាតិ និងពង្រឹងទំនាក់ទំនងការទូតឱ្យកាន់តែប្រសើរឡើង ជាមួយនឹងបណ្ដាប្រទេសនានាក្នុងសកលលោក។

ខ្ញុំសង្ឃឹមថា ក្នុងឆ្នាំថ្មីនេះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ប្ដេជ្ញាចិត្តនឹងបន្តខិតខំបំពេញភារកិច្ចជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ យើងឱ្យឈានទៅមុខប្រកបដោយជោគជ័យថ្មីៗថែមទៀត ដើម្បីនាំមកនូវមោទនភាពជាតិជូនព្រះរាជាណាចក្រកម្ពុជា និងលើកស្ទួយកិត្យានុភាពជាតិ ឱ្យកាន់តែមានកេរ្តិ៍ឈ្មោះល្បីសុសសាយថែមទៀត នៅលើឆាកអន្តរជាតិ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រទានពរជ័យសិរីមង្គលជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងក្រុមគ្រួសារ ឱ្យប្រកបតែសេចក្ដីសុខ សុភមង្គល សុខភាពល្អបរិបូណ៌ ជានិច្ចនិរន្តន៍ និងសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ៦ កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩

**ប្រាក់ សុខុន**

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh